# ហលិទ្ទិរាគជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារិកា បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **សុតិតិក្ខំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្នរបស់ជាតកនេះ នឹងមានជាក់ច្បាស់ក្នុង**ចូឡនារទជាតក** ក្នុងតេរសកនិបាតឯណោះ ។ ចំណែករឿងក្នុងអតីត (ព្រះពោធិសត្វកាលករិយារបស់ខ្លួនស្លាប់ហើយ គិតថា សេចក្តីស្លាប់មានដល់ករិយាជាទីស្រឡាញ់របស់យើង យ៉ាងណា សេចក្តីស្លាប់នោះនឹងមានដល់យើង ក៏យ៉ាងនោះ ទើបនាំកូនរបស់ខ្លួន ទៅព្រៃហិមពាន្ត បួសជាឥសី ញុំាងឈានអភិញ្ញាកើតឡើង មានមើមឈើនិងផ្លែឈើក្នុងព្រៃជាអាហារ ក្នុងពេលនោះ ពួកចោរក្នុងបច្ចន្តជនបទចូលមកប្លន់អ្នកស្រុក ហើយចាប់មនុស្សយកទៅធ្វើជាឈ្លើយ ក្នុងបណ្តាលឈ្លើយទាំងនោះ មានកុមារិកាម្នាក់ បានរត់រួច ហើយក៏មកដល់អាស្រមរបស់តាបស ចំពេលដែលតាបសជាបិតា ចូលទៅរកមើមឈើផ្លែឈើ) កុមារិកានោះ (ក៏បានឱកាស) ទម្លាយសីលរបស់តាបសកុមារនោះ និងដឹងភាពដែលតាបសនោះបិតក្នុងអំណាចរបស់ខ្លួនហើយ គិតថា យើងនឹងបោកបញ្ឆោតតាបសនេះ ហើយនឹងនាំទៅកាន់ស្រុកមនុស្ស ដូច្នេះហើយ

*ពោលថា ឈ្មោះថា សីលដែលរក្សាក្នុងព្រៃ ជាទីវៀរចាកកាមគុណទាំងឡាយមានរូបជាដើម រមែងមិនមានផលច្រើន សីលដែលរក្សាក្នុងស្រុកមនុស្សជាទីតាំងនៃកាមគុណទាំងឡាយ មានរូបជាដើម ទើបមានផលច្រើន លោកចូរមក ទៅទីនោះជាមួយនឹងខ្ញុំ ព្រៃនឹងជាប្រយោជន៍អ្វីដល់លោក ពោលយ៉ាងនេះហើយ ទើបពោលគាថាទី ១ ថា*

**សុតិតិក្ខំ អរញ្ញម្ហិ, បន្តម្ហិ សយនាសនេ;**
**យេ ច គាមេ តិតិក្ខន្តិ, តេ ឧឡារតរា តយា ។**

***ការដែលលោកអត់ទ្រាំក្នុងព្រៃ ជាសេនាសនៈដ៏ស្ងាត់ ជាការប្រពៃហើយ តែថាពួកជនណាអត់ទ្រាំនៅក្នុងស្រុក ពួកជននោះ ឈ្មោះថា ប្រសើរលើសលុប ជាងលោកទៅទៀត ។***

*បណ្ដាបទទាំងបទថា* **សុតិតិក្ខំ** *សេចក្ដីថា ការអត់ធន់ដោយល្អ ។ បទថា* **តិតិក្ខន្តិ** *សេចក្ដីថា ការអត់ធន់នឹងត្រជាក់ជាដើម ។*

*តាបសកុមារស្ដាប់ពាក្យនោះហើយ ពោលថា បិតារបស់ខ្ញុំទៅព្រៃ កាលបិតារបស់ខ្ញុំមក ខ្ញុំនឹងលាគាត់ ហើយខ្ញុំនឹងទៅ ។ នាងកុមារិកានោះគិតថា បានឮថា តាបសនេះមានបិតា បើបិតារបស់តាបសនេះនឹងឃើញយើង គាត់នឹងវាយយើងដោយចុងដងរែក ឲ្យយើងដល់នូវសេចក្ដីវិនាស យើងគួរទៅមុន ។ លំដាប់នោះ កុមារិកាពោលនឹងកុមារតាបសថា បើយ៉ាងនោះ ខ្ញុំនឹងធ្វើគ្រឿងសម្គាល់ផ្លូវទុក ខ្ញុំនឹងទៅមុន លោកចូរមកតាមក្រោយចុះ ថាដូច្នេះនាងក៏ចេញទៅ ។ តាបសនោះ កាលនាងកុមារិកាទៅហើយ ក៏មិននាំឧសមកទុក មិនតម្កល់ទឹកប្រើប្រាស់ និងទឹកផឹក គិតតែអង្គុយសញ្ជប់សញ្ជឹងតែប៉ុណ្ណោះ កាលបិតាមក ក៏មិនការក្រោកទទួល ។ គ្រានោះ បិតាសូម្បីដឹងថា កូននេះលុះក្នុងអំណាចស្ត្រីហើយ ក៏ពោលនឹងតាបសនោះថា នែកូន ព្រោះហេតុអ្វី បានជាអ្នកមិននាំឧសមកទុក មិនតម្កល់ទឹកប្រើប្រាស់និងទឹកផឹក ហើយអង្គុយសញ្ជប់សញ្ជឹងចឹង ។ ពេលនោះ តាបសកុមារពោលនឹងបិតាថា បពិត្របិតា បានឮថា សីលដែលរក្សាក្នុងព្រៃ ឈ្មោះថា មិនមានផលច្រើន ការរក្សាសីលក្នុងស្រុកមនុស្សទើបមានផលច្រើន ខ្ញុំនឹងទៅរក្សាសីលនៅទីនោះ សម្លាញ់របស់ខ្ញុំពោលនឹងខ្ញុំថា អ្នកគប្បី*

មក គេទៅមុនហើយ ខ្ញុំទៅរកគេ តើបុរសណាមួយ ដែលខ្ញុំគប្បីសេពដោយការនៅ ក្នុងទីនោះ ដូច្នេះកាលនឹងសួរ ទើបពោលគាថាទី ២ ថា

អរញ្ញា គាមមាគម្ម, កឹសីលំ កឹវតំ អហំ;
បុរិសំ តាត សេវេយ្យំ, តំ មេ អក្ខាហិ បុច្ឆិតោ។

បពិត្របិតា លុះដល់ខ្ញុំចេញអំពីព្រៃមកកាន់ស្រុក តើគួរសេពគប់បុរសមានសីលដូចម្ដេច មានវត្តដូចម្ដេច ខ្ញុំសួរហើយ សូមបិតាប្រាប់ហេតុនោះ ។

លំដាប់នោះ បិតាកាលសម្ដែងប្រាប់ ទើបពោលគាថាដ៏សេសថា

យោ តេ វិស្សាសយេ តាត, វិស្សាសញ្ច ខមេយ្យ តេ;
សុស្សូសី ច តិតិក្ខី ច, តំ ភជេហិ ឥតោ គតោ។

នែបា បើបុគ្គលណាស្និទ្ធស្នាលនឹងអ្នក ថែមទាំងគាប់ចិត្តនឹងសេចក្ដីស្និទ្ធស្នាលរបស់អ្នក ហើយស្ដាប់បង្គាប់ និងអត់ទ្រាំ (នូវពាក្យសំដី) អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់បុគ្គលនោះចុះ ។

យស្ស កាយេន វាចាយ, មនសា នត្ថិ ទុក្កដំ;
ឧរសីវ បតិដ្ឋាយ, តំ ភជេហិ ឥតោ គតោ។

បុគ្គលណាមិនមានអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកចេញអំពីព្រៃនេះទៅ ចូរតាំងខ្លួនដូចជាកូន ហើយសេពគប់បុគ្គលនោះចុះ ។

យោ ច ធម្មេន ចរតិ, ចរន្តោបិ ន មញ្ញតិ;
វិសុទ្ធការិំ សប្បញ្ញំ, តំ ភជេហិ ឥតោ គតោ។

មួយទៀត បុគ្គលណាប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន លុះដល់អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់នូវបុគ្គល ដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយប្រាជ្ញានោះចុះ ។

ហាលិទ្ទិរាគំ កបិចិត្តំ, បុរិសំ រាគវិរាគិនំ;
តាទិសំ តាត មា សេវិ, និម្មនុស្សម្បិ ចេ សិយា។

*នែបា បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់រមៀត មានចិត្តដូចស្វា ត្រេកអរហើយ ប្រែជាមិនត្រេកអរវិញ បើទុកជា (ក្នុងជម្ពូទ្វីបនេះ) មិនមានមនុស្សសោះ អ្នកកុំគប់រកបុរសបែបនោះឡើយ ។*

អាសីវិសំវ កុបិតំ, មីឡ្ហលិត្តំ មហាបថំ;
អារកា បរិវជ្ជេហិ, យានីវ វិសមំ បថំ។

*អ្នកចូរចៀសវាង (បុគ្គលបែបនោះ) អំពីចម្ងាយ ឲ្យដូចបុគ្គលចៀសវាងអាសិរពិសដែលក្រោធ ឬចៀសវាងផ្លូវធំ ដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលអ្នកទៅដោយយានចៀសវាងផ្លូវមិនស្មើ ។*

អនត្ថា តាត វឌ្ឍន្តិ, ពាលំ អច្ចុបសេវតោ;
មាស្សុ ពាលេន សំគច្ឆិ, អមិត្តេនេវ សព្ពទា។

*នែបា អំពើមិនជាប្រយោជន៍ទាំងឡាយ តែងចម្រើនដល់បុគ្គល ដែលគប់រកបុគ្គលពាល អ្នកកុំគប់រកបុគ្គលពាល ដែលដូចជាសត្រូវសព្វ ៗ កាលឡើយ ។*

តំ តាហំ តាត យាចាមិ, ករស្សុ វចនំ មម;
មាស្សុ ពាលេន សំគច្ឆិ, ទុក្ខោ ពាលេហិ សង្គមោ។

*នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យយើង ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ ( ព្រោះ) ការគប់រកនូវបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខ ។*

*តាបសកំលោះកាលស្តាប់ឱវាទរបស់បិតាយ៉ាងនេះហើយ ពោលថា បពិត្របិតា ខ្ញុំទៅកាន់ស្រុកមនុស្សហើយ នឹងមិនបានបណ្ឌិតដែលដូចបិតា ខ្ញុំខ្លាចការទៅស្រុកមនុស្ស ខ្ញុំនឹងនៅក្នុងសម្នាក់របស់បិតាក្នុងទីនេះឯង ។ លំដាប់នោះ បិតាកាលឱវាទដល់កូនឲ្យក្រៃលែងឡើងហើយ ក៏ប្រាប់ការបរិកម្មកសិណ ។ មិនយូរប៉ុន្មាន តាបសកំលោះបានញ៉ាំងអភិញ្ញាសមាបត្តិឲ្យកើតឡើង ហើយជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ជាមួយនឹងបិតា ។*

*ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាកត ក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ឧក្កណ្ឋិតភិក្ខុបានតាំងនៅក្នុងសោតាបត្តិផល ។*

**តទា តាបសកុមារោ ឧក្កណ្ឋិតភិក្ខុ អហោសិ** *តាបសកុមារក្នុងកាលនោះ បានមកជាឧក្កណ្ឋភិក្ខុ*

**កុមារិកា ថុល្លកុមារិកាវ** *កុមារិកាបានមកជាថុល្លកុមារិកា*

**បិតា តាបសោ បន អហមេវ អហោសិំ** *ចំណែកតាបសជាបិតា គឺ តថាគត នេះឯង ។*

*ចប់ ហលិទ្ទិរាគជាតក ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក នវកនិបាត បិដកលេខ ៥៩ ទំព័រ ១៥៣)*

*ថ្ងៃអង្គារ ១០ កើត ខែវិសាខ ឆ្នាំច សំរិទ្ធិស័ក ច.ល. ១៣៨០*

*ថ្ងៃទី ២៤ ខែមេសា ព.ស. ២៥៦១ គ.ស.២០១៨*

*ដោយ ស.ដ.វ.ថ.*